# កសិករកម្ពុជាស្វែងរកហេតុផលដើម្បីបន្តរស់ នៅលើដីរបស់ខ្លួន

**ខេត្តកំពង់ចាម ប្រទេសកម្ពុជា** - មិត្តភក្តិភាគច្រើនរបស់ លោកងិន ផុន បានចាកចេញពីភូមិអស់ទៅហើយ មុនពេលដែលគាត់សម្រេចចិត្តទៅតាមគេដែរ។ ការងារនៅចម្ការកៅស៊ូ ប្រហែលជាអាចឲ្យគាត់រកប្រាក់បានគ្រប់គ្រាន់ មកបង្កើតចម្ការដោយខ្លួនឯង នៅថ្ងៃណាមួយ ដែលអាចផ្តល់ប្រាក់ចំណេញមកឲ្យគាត់វិញ។ ប៉ុន្តែ ដើម្បីសម្រេចបំណងនេះ គាត់ចាំបាច់ត្រូវចាកចេញពីផ្ទះ។

បីឆ្នាំក្រោយ លោកងិន ផុន និងប្រពន្ធរបស់គាត់ អ្នកស្រីគឹម ស៊ីថុល បានត្រឡប់មកវិញជាមួយនឹងប្រាក់ចំនួន ៣.០០០ ដុល្លារ ដែលពួកគេប្រើប្រាស់ដើម្បីពង្រីកដីដែលមានទំហំតូចល្មមរបស់ពួកគាត់ នៅក្នុងឃុំស្វាយពក ខេត្តកំពង់ចាម ឲ្យបានកាន់តែធំជាងមុន។ តាមរយៈការពង្រីកការដាំដុះដំណាំឲ្យបានច្រើនមុខ ពួកគាត់បានទទួលផលត្រឹមតែល្មមគ្រប់គ្រាន់សម្រាប់ចិញ្ចឹមជីវិតប៉ុណ្ណោះ ដែលធ្វើឲ្យពួកគាត់នៅតែងាយរងគ្រោះ ប្រសិនបើមានវិបត្តិសេដ្ឋកិច្ចអ្វីមួយកើតមានឡើង ដូចជានៅពេលដែលការប្រមូលផលមិនសូវបានល្អ និងនៅពេលដែលតម្លៃដំណាំធ្លាក់ចុះទាបជាដើម។

លោក ផុន បាននិយាយថា "ជម្រើសដែលយើងមាន គឺអាចទៅរកការងារធ្វើនៅចម្ការកៅស៊ូ ឬត្រូវទៅទីក្រុងភ្នំពេញដើម្បីធ្វើការងារតាមការដ្ឋានសំណង់"។

នេះគឺជាជម្រើសសម្រាប់ប្រជាជនខ្មែររស់នៅជនបទជាច្រើននាក់ ខណៈពេលដែលពួកគេត្រូវធ្វើការងារលំបាកលំបិនជាច្រើនម៉ោងនៅលើដីស្រែចម្ការ ហើយជារឿយៗទទួលបានផលតិចតួចមកវិញ។ នៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ភាពក្រីក្រក្នុងប្រទេសកម្ពុជា បានថយចុះយ៉ាងគំហុក ប៉ុន្តែសម្រាប់ប្រជាពលរដ្ឋជាច្រើនដែលរស់នៅតាមតំបន់ជនបទ ដែលជាកន្លែងរស់នៅរបស់ប្រជាពលរដ្ឋភាគច្រើននៅក្នុងប្រទេសផងដែរនោះ ជីវិតគឺនៅតែជួបការលំបាក ដោយសូម្បីតែវិបត្តិសេដ្ឋកិច្ចតិចតួចក៏អាចរុញច្រានឲ្យពួកគេធ្លាក់ចូលក្នុងភាពក្រីក្រធ្ងន់ធ្ងរវិញផងដែរ។

## ការចាកចោលស្រែចម្ការ

កសិករក្រីក្រជាច្រើននាក់ចាកចេញពីភូមិរបស់ខ្លួន ដើម្បីរកការងារដែលផ្តល់ប្រាក់កម្រៃច្រើនជាងមុននៅក្នុងទីក្រុងភ្នំពេញ ឬទៅធ្វើការងារតាមទីប្រជុំជន ដែលនៅក្បែរខាងស្រុកកំណើតរបស់ខ្លួន ឬទៅធ្វើការងារនៅតាមចម្ការកៅស៊ូ និងចម្ការស្វាយចន្ទី។ របាយការណ៍មួយដែលចេញផ្សាយនៅឆ្នាំ ២០១២ ដោយក្រសួងផែនការរបស់ប្រទេសកម្ពុជា បានកត់សម្គាល់ថា ក្នុងភូមិជនបទដែលត្រូវបាន

សិក្សាសម្រាប់របាយការណ៍នេះ មានការបាត់បង់ប្រជាជនជាមធ្យម ៤ ភាគរយ កាលពីឆ្នាំមុននេះ ដោយសារការធ្វើចំណាកស្រុក ភាគច្រើនមកកាន់ទីក្រុងភ្នំពេញ។

ជាមួយនឹងប្រជាជនជាង ៨០ ភាគរយ នៅពឹងអាស្រ័យលើវិស័យកសិកម្មសម្រាប់ជាមុខរបរចិញ្ចឹមជីវិត កិច្ចខិតខំប្រឹងប្រែងកាត់បន្ថយភាពក្រីក្រនាពេលអនាគតរបស់ប្រទេសកម្ពុជា គឺត្រូវពឹងផ្អែកលើការធ្វើយ៉ាងណាឲ្យការងារកសិកម្មនៅក្នុងប្រទេសនេះ កាន់តែមានប្រសិទ្ធភាពជាងមុន។ បើតាមការលើកឡើងរបស់មន្ត្រីរដ្ឋាភិបាល ការងារដ៏សំខាន់គឺត្រូវបន្តធ្វើយ៉ាងណាឲ្យគ្រួសារជនបទរស់នៅលើដីរបស់ខ្លួន។

ជាការពិត ប្រាក់ដែលពលករចំណាកស្រុកផ្ញើមកផ្ទះវិញ អាចផ្តល់ជាប្រយោជន៍ដល់ភូមិកររបស់ខ្លួន។ ប៉ុន្តែការចាកចេញរបស់ប្រជាជនក្នុងចំនួនច្រើនដែលរបាយការណ៍របស់រដ្ឋាភិបាលមួយនេះរៀបរាប់ថា "ខ្ពស់មិនធ្លាប់មាន" អាចជាការដាក់សម្ពាធយ៉ាងធ្ងន់ធ្ងរមកលើទីក្រុង ដោយសារវានាំឲ្យចំនួនប្រជាជនតាមទីក្រុងទាំងអស់នេះមានការកើនឡើង ហើយស្របពេលជាមួយគ្នា ចរន្តបែបនេះបន្សល់ទុកកុមារ និងចាស់ជរាឲ្យរស់នៅក្នុងភូមិ។ ដំណោះស្រាយដែលមាននិរន្តរភាពចំពោះការកាត់បន្ថយភាពក្រីក្រនៅតំបន់ជនបទ គឺត្រូវផ្តល់ឱកាសឲ្យបានច្រើនជាងមុនដល់កសិករ ដើម្បីឲ្យពួកគេកាន់តែមានផលិតភាព និងកាន់តែអាចរកប្រាក់ចំណូលបានច្រើនជាងមុន។

ភាពចាំបាច់ទាំងនេះកាន់តែមានភាពស្រួចស្រាវទៅទៀត ជាពិសេសនៅក្នុងតំបន់ជុំវិញបឹងទន្លេសាបដែលស្ថិតនៅភាគកណ្តាលនៃប្រទេសកម្ពុជា។ ផ្ទៃរងទឹកភ្លៀងធម្មជាតិដ៏ធំនេះ មានបឹងទឹកសាបធំជាងគេនៅអាស៊ីអាគ្នេយ៍ ហើយមួយភាគបីនៃប្រជាជនសរុបរបស់ប្រទេសកម្ពុជារស់នៅក្នុងតំបន់នេះ។

អស់រយៈពេលរាប់សតវត្សរ៍មកហើយដែលតំបន់អំណោយផលសម្រាប់ការធ្វើកសិកម្ម និងនេសាទនេះ បានផ្តល់នូវស្បៀងអាហារ និងប្រភពចិញ្ចឹមជីវិតដល់ប្រជាពលរដ្ឋកម្ពុជារាប់ជំនាន់តៗគ្នាមក។ ទោះជាយ៉ាងណាក៏ដោយ អត្រានៃភាពក្រីក្រនៅតំបន់នេះ នៅតែមានកម្រិតខ្ពស់ ពោលគឺគ្រួសារជាងពាក់កណ្តាលដែលរស់នៅជុំវិញបឹងទន្លេសាបនេះ មិនទាំងអាចបង្កបង្កើនផលស្រូវឲ្យបានគ្រប់គ្រាន់ ដើម្បីបំពេញតម្រូវការរបស់ពួកគេឡើយ។

## មធ្យោបាយសម្រាប់រកចំណូលឲ្យបានកាន់តែខ្ពស់ជាងមុន

សម្រាប់ លោកផុន អាយុ ៤០ឆ្នាំ និង ប្រពន្ធរបស់គាត់ អ្នកស្រីស៊ីថុល អាយុ ៤២ ឆ្នាំ ការធ្វើចំណាកស្រុក មិនមែនជាការសម្រេចចិត្តដែលពិបាកប៉ុន្មាននោះទេ ដោយសារតែចម្ការកៅស៊ូដែលពួក

គេទៅធ្វើការស្ថិតនៅក្នុងខេត្តតែមួយ ដែលពួកគេកំពុងរស់នៅ។ បីឆ្នាំក្រោយមក ពួកគេសន្សំលុយបាន គ្រប់គ្រាន់ដើម្បីយកមករៀបចំដី បម្លែងពីវាលស្រែទៅជាចម្ការពោត និងសាងសង់របងទៀតផង។

ចម្ការនេះបានផ្តល់ឲ្យពួកគេនូវមធ្យោបាយរឹងមាំសម្រាប់បង្កើនប្រាក់ចំណូល។ ប៉ុន្តែពួកគេត្រូវការជំបូន្មានជាច្រើន ដូចជាអំពីប្រភេទដំណាំដែលត្រូវដាំ ប្រភេទជីដែលត្រូវប្រើប្រាស់ និងរបៀបរកបានតម្លៃសមរម្យសម្រាប់កសិផលរបស់ពួកគេ។ ពួកគេក៏ត្រូវការទុនបន្ថែមទៀតសម្រាប់ទិញគ្រាប់ពូជ និងទិញសម្ភារៈសម្រាប់ស្រោចស្រពដំណាំឲ្យកាន់តែល្អផងដែរ។

លោកផុន បានបន្តពង្រីកដីចម្ការរបស់គាត់ ដោយបន្ថែមមុខប្រភេទដំណាំថ្មីៗ និងថែមទាំងបានជីកស្រះចិញ្ចឹមត្រីមួយផង បន្ទាប់ពីបានទទួលជំនួយតាមរយៈគម្រោងមួយដែលគាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ផ្តោតលើគ្រួសារក្រីក្ររស់នៅតាមទីជនបទ។

កន្លងមក គម្រោងកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍កសិកម្មខ្នាតតូចនៅតំបន់ទន្លេសាប បានជួយដល់ប្រជាពលរដ្ឋជិត ៤០.០០០ គ្រួសារដែលរស់នៅជុំវិញបឹងទន្លេសាប តាមរយៈការផ្តល់លទ្ធភាពឲ្យពួកគេអាចទទួលបានបច្ចេកវិទ្យា ទីផ្សារ ឥណទាន ហើយប្រហែលសំខាន់ជាងគេនោះគឺការផ្តល់ឲ្យពួកគេនូវចំណេះដឹងកាន់តែល្អប្រសើរជាងមុន។

លោក សុខ នឿន ទីប្រឹក្សាគម្រោងដែលធ្វើការងារជាមួយនឹងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានពន្យល់ថា "យើងបានបង្រៀនកសិករឲ្យចេះបច្ចេកទេសថ្មីៗ ដូចជា ការដាំដំណាំឆ្លាស់ និងការបណ្តុះផ្សិតចំបើងជាដើម។ បច្ចេកទេសទាំងនេះអាចឲ្យពួកគេរកចំណូលបានពេញមួយឆ្នាំ"។

**លោកងិន ផុន និយាយថា "ជារឿយៗ ខ្ញុំបានគិតថា ចង់ចាកចេញពីទីនេះ ប៉ុន្តែខ្ញុំប្តូរចិត្តវិញ បន្ទាប់ពីបានទទួលការគាំទ្រពីគម្រោង ADB នេះ"។**

គោលបំណងមួយរបស់គម្រោងនេះ គឺបង្កើតភាពងាយស្រួលឲ្យកសិករអាចធ្វើការងារលើដីរបស់ខ្លួនជាជាងធ្វើចំណាកស្រុក។ ដោយសារតែប្រទេសកម្ពុជាស្ថិតក្នុងចំណោមប្រទេសដែលមានទិន្នផលស្រូវក្នុងមួយហិចតាទាបជាងគេនៅអាស៊ី កសិករអាចទិញស្រូវពូជដែលមានគុណភាពខ្ពស់ដែលផលិតដោយគម្រោងនេះផ្ទាល់តែម្តង ដើម្បីបង្កើនទិន្នផលខ្លួន។ ក្រុមកែលម្អជីវភាពរស់នៅ ដែលមានសមាជិកជាគ្រួសារក្រីក្រទទួលបានឥណទានខ្នាតតូចដែលអាចយកទៅវិនិយោគសម្រាប់អាជីវកម្មដែលផ្តល់ប្រាក់ចំណេញបានច្រើន ដូចជា ការចិញ្ចឹមសត្វជាដើម។

ដោយកំពុងដកពោតបណ្តើរ លោកផុនបានពន្យល់ថា គាត់បានយកកម្ចីខ្នាតតូចនេះទៅទិញឧបករណ៍ល្អៗ គ្រាប់ពូជដែលមានគុណភាពល្អ ធ្វើទ្រុងមាន់ និងជីកស្រះត្រីនៅខាងក្រោយដីរបស់គាត់។ ចំណូលប្រចាំខែរបស់គាត់បានកើនឡើងទ្វេដងដល់ប្រមាណជា ៨០០.០០០ រៀល ឬ ២០០ ដុល្លារ ក្នុងមួយខែ។

លោកផុនបាននិយាយថា "ឥឡូវនេះ ខ្ញុំអាចផលិតស្បៀងអាហារ ដូចជា អង្ករ បន្លែ មាន់ និងត្រីបានច្រើនជាងមុនដល់ទៅប្រាំដង។ កន្លងមក ខ្ញុំតែងតែគិតថា ចង់ចាកចេញពីកន្លែងនេះ ប៉ុន្តែខ្ញុំបានប្តូរចិត្តបន្ទាប់ពីបានទទួលការគាំទ្រពីគម្រោង ADB នេះ"។

## ការប្រែក្លាយកសិកម្មខ្នាតតូចឲ្យទៅជាអាជីវកម្មខ្នាតតូច

គម្រោងនេះកំពុងជួយប្រែក្លាយកសិកម្មខ្នាតតូចឲ្យទៅជាអាជីវកម្មខ្នាតតូច។ គ្រួសារដែលចូលជាសមាជិកក្រុមកែលម្អជីវភាពរស់នៅ ត្រូវធ្វើផែនការអាជីវកម្មសាមញ្ញមួយទៅឲ្យក្រុមរបស់ខ្លួន ប្រសិនបើពួកគេចង់បានកម្ចីពីមូលនិធិវិលជុំនេះ។

កាលពីឆ្នាំមុន អ្នកស្រី យ៉ា សុត អាយុ ៣៩ ឆ្នាំ ដែលមានកូនបួននាក់ បានខ្ចីកម្ចីប្រមាណជា ២៥០ ដុល្លារ ដើម្បីធ្វើ "ស្រូវរដូវប្រាំង" ក្នុងភូមិរបស់គាត់នៅក្នុងស្រុកស្ទឹងសែន ខេត្តកំពង់ធំ។ គាត់បាននិយាយថា "ប្រសិនបើយើងមិនយល់ ឬ មិនចេះធ្វើផែនការអាជីវកម្ម យើងអាចសាកសួរប្រធានក្រុមបាន"។

ដោយសារការធ្វើស្រែត្រូវពឹងផ្អែកលើទឹកភ្លៀង កសិករជាច្រើនរួមទាំងអ្នកស្រីសុតជ្រើសរើសយកការដាំដុះពូជស្រូវស្រាល ដែលអាចឲ្យគាត់ដាំដំណាំរួមផ្សំផ្សេងៗទៀតបានក្រោយពីការប្រមូលផលស្រូវស្រាលរួច។ ការធ្វើបែបនេះ អាចឲ្យគាត់ដាំដំណាំបានច្រើនដង បើធៀបជាមួយនឹងកន្លែងដែលដាំដុះពូជស្រូវធ្ងន់។

ឥឡូវនេះ អ្នកស្រីសុត អាចរកប្រាក់បាន ៧ លានរៀល ក្នុងមួយរដូវៗ ដែលមានរយៈពេលបីខែ។ អង្គុយនៅក្រៅផ្ទះពីរជាន់របស់គាត់ គាត់រំឭកឡើងវិញថា "កាលពីមុន ខ្ញុំបានគ្រោងធ្វើចំណាកស្រុកដូចគេដូចឯងដែរ ដោយសារតែខ្ញុំពុំមានលុយចិញ្ចឹមកូន។ ប្រសិនបើពុំអាចរកចំណូលបន្ថែមបានទេ ខ្ញុំមិនអាចឲ្យកូនៗបន្តរៀននៅសាលាបានឡើយ។"

អ្នកជិតខាងរបស់គាត់ម្នាក់ឈ្មោះ តុន គឹមហួយ ធ្លាប់រកត្រី ជាការបំពេញបន្ថែមលើមុខរបរចិញ្ចឹមជីវិតរបស់គាត់។ សម្រាប់គ្រួសាររបស់គាត់ ត្រឹមតែរកបានមួយចម្អែតក្រពះប្រចាំថ្ងៃ ក៏ជាការ

ពិបាកដែរ។ ប្រជាពលរដ្ឋជនបទជាច្រើនគ្រួសារដែលរស់នៅជុំវិញបឹងទន្លេសាប ជួបប្រទះនឹងបញ្ហាខ្វះទឹកភ្លៀងតាមរដូវ។

**អ្នកស្រី តុន គឹមហួយ និយាយថា "ខ្ញុំមានគម្រោងដាក់ពាក្យសុំកម្ចីបន្ថែមទៀត ហើយយកលុយនេះទិញមាន់មកចិញ្ចឹមបន្ថែម ដើម្បីបង្កើនប្រាក់ចំណូលសម្រាប់គ្រួសាររបស់ខ្ញុំ។"**

នេះមានន័យថា ជារឿយៗ កសិករនៅក្នុងភូមិរបស់ អ្នកស្រីគឹមហួយ ពុំមានទឹកស្អាត សម្រាប់ប្រើប្រាស់ក្នុងគ្រួសារជាប្រចាំឡើយ។ ប្រព័ន្ធធារាសាស្រ្តក៏ពុំមានការអភិវឌ្ឍន៍ឲ្យបានល្អ ហើយកសិករជាច្រើននាក់មិនដឹងពីរបៀបប្រើប្រាស់ទឹកដែលខ្លួនមានឲ្យមានប្រសិទ្ធភាពឡើយ។

នៅក្នុងតំបន់ទន្លេសាប មានការបាត់បង់ទឹកជាច្រើន ដោយសារទឹកត្រូវហូរចាក់ទៅក្នុងបឹងវិញ។ មានន័យថា ពេលខ្លះ ប្រជាពលរដ្ឋពុំមានទឹកបរិភោគឲ្យបានគ្រប់គ្រាន់ក្នុងរដូវប្រាំងឡើយ។ បញ្ហាខ្វះទឹកនេះ ក៏អាចរួមចំណែកធ្វើឲ្យការប្រមូលផលមិនបានល្អ និងធ្វើឲ្យមានបញ្ហាកង្វះស្បៀងអាហារផងដែរ។

## ការចាប់ផ្តើមជាថ្មី

អ្នកស្រីគឹមហួយ គិតថាគ្រួសាររបស់គាត់នឹងមិនជួបប្រទះនឹងភាពអត់ឃ្លានទៀតឡើយ ប្រសិនបើគាត់អាចចិញ្ចឹមមាន់ និងបង្កបង្កើនផលស្រូវដោយខ្លួនឯងបាន។ គាត់ដាក់ពាក្យសុំកម្ចី ២០០ ដុល្លារពីមូលនិធិវិលជុំរបស់គម្រោង ដើម្បីយកទៅទិញកូនមាន់ដែលបានចាក់វ៉ាក់សាំងរួចជាស្រេច ពីកន្លែងភ្ញាស់កូនមាន់ ដែលបានទទួលការគាំទ្រពីគម្រោងនេះ ហើយលុយកម្ចីដែលនៅសល់ គាត់បានយកទៅទិញស្រូវ។ ស្រូវនេះ គឺយកមកប្រើជាចំណីឲ្យមាន់ផង និងយកមកកិនជាអង្ករសម្រាប់ហូបនៅក្នុងគ្រួសារផង។ ចំណូលដែលគាត់រកបានបន្ថែម ៧០ ដុល្លាបន្ថែមក្នុងមួយខែ អាចឲ្យគាត់ទិញម្ហូបអាហារបន្ថែមបាននៅពេលដែលចាំបាច់។

អ្នកស្រីគឹមហួយ បាននិយាយថា "ពេលនេះ យើងមានអាហារញ៉ាំច្រើនជាងមុន។ ខ្ញុំមានគម្រោងដាក់ពាក្យសុំកម្ចីបន្ថែមទៀត ហើយយកលុយនេះទិញមាន់មកចិញ្ចឹមបន្ថែម ដើម្បីបង្កើនប្រាក់ចំណូលសម្រាប់គ្រួសាររបស់ខ្ញុំ។"

លោកផុន នឹងមិនចាកចេញពីដីរបស់គាត់ទៀតឡើយ។ តាមពិតចំណូលច្រើនជាងមុនរបស់គាត់បែបនេះ អាចធ្វើឲ្យគ្រួសាររបស់គាត់នៅជុំគ្នាជាលើកដំបូងមិនធ្លាប់មាន ក្នុងរយៈពេលប៉ុន្មានឆ្នាំ

នេះ។ គាត់ចង់ឲ្យកូនប្រុសរបស់គាត់ត្រឡប់មកពីទីក្រុងភ្នំពេញវិញ បន្ទាប់ពីគាត់បញ្ចប់ការសិក្សាជាជាងជួសជុលគ្រឿងម៉ាស៊ីន។

"ខ្ញុំគិតចង់បើកកន្លែងជួសជុលឲ្យគាត់នៅលើដីចម្ការរបស់ខ្ញុំតែម្តង ដើម្បីឲ្យគាត់អាចធ្វើការនៅទីនេះជាមួយយើងបាន"។